សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា
Cambodia Indigenous Youth Association



# ឧបករណ៍ភ្លេងឃ្មោះ

ចងក្រងដោយ៖ ក្រុមនិស្សិតជនជាតិដើមភាគតិច

កាលបរិច្ឆេទ ៖ ខែធ្នូ ឆ្នាំ២០២៥

## អារម្ភកថា

បន្ទាប់ពីក្រុមយើងខ្ញុំ បានរៀនវគ្គស្ដីពីការសិក្សាស្រាវជ្រាវដែលរៀបចំដោយសមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (ស.យ.ជ.ក) រយៈពេល ២ថ្ងៃ ឃើញថាក្រុមយើងខ្ញុំបានចាប់អារម្មណ៍ក្នុងការចុះទៅសិក្សាស្រាវជ្រាវនៅសហគមន៍មូលដ្ឋាន ដែលជាសហគមន៍ជនជាតិដើមភាគតិចពូនង ចង់ដឹងពីការប្រើប្រាស់ឧបករណ៍ភ្លេងឃ្មោះតាមបែបប្រពៃណីទំនៀមទម្លាប់ កម្មវិធីផ្សេងៗទៀត ដែលគេតែងតែយកមកប្រើប្រាស់ក្នុងកម្មវិធីផ្សេងៗគ្នាជាដើម។ ដោយយោងតាមចំណេះដឹងទាំងអស់នេះបានជាមានឱកាស និងមានលទ្ធភាពបានសិក្សាស្រាវជ្រាវមួយ សម្រាប់ទុកជាឯកសារដល់យុវជនជំនាន់ក្រោយ។ នេះគឺជាឱកាសយ៉ាងវិសេសវិសាលបំផុត សម្រាប់វាស់ស្ទង់នូវចំណេះដឹងដែលមានពីមុនមក និងសិក្សាស្រាវជ្រាវបន្ថែមទៀត។ ហេតុនេះហើយទើបក្រុមយើងខ្ញុំ បានសម្រេចចិត្តក្នុងការជ្រើសរើសយកប្រធាន បទមួយដែលទាក់ទងនិង «ឧបករណ៍ភ្លេងឃ្មោះជនជាតិដើមភាគតិចពូនង» មកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវ ដោយសារតែមានចំណុចជាច្រើនដែលជាបញ្ហាចោទត្រូវសិក្សា និងស្វែងរកពីដំណោះស្រាយផងដែរ។

កម្មវត្ថុសំខាន់មួយទៀតនោះចង់ឱ្យយុវជនជំនាន់ក្រោយ និងសាធារណ-ជនបានយល់ដឹងអំពីបញ្ហាប្រឈមនៃការបាត់បង់ទំនៀមទម្លាប់ប្រពៃណី មិនមានការចងក្រង និងបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយបានដឹងអំពីឃ្មោះជនជាតិដើមភាគតិចពូនងនេះ ព្រមទាំងវិធានការដោះស្រាយមួយចំនួនដែលអាចកើតមានឡើង។

ជាចុងក្រោយ ក្រុមយើងខ្ញុំសូមគោរពទទួលយកនូវរាល់កំហុសឆ្គាំឆ្គងណាមួយដោយអចេតនា ឬមានភាពខ្វះចន្លោះត្រង់កន្លែងណាមួយ សូមមេត្តាខន្តីអភ័យទោសដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីក្រុមយើងខ្ញុំ និងរង់ចាំទទួលនូវមតិកែលម្អរាល់ចំណុចខ្វះខាតទាំងឡាយក្នុងន័យស្ថាបនា ដើម្បីឱ្យការស្រាវជ្រាវមួយនេះកាន់តែមានអត្ថន័យគ្រប់គ្រាន់បន្ថែមទៀត។ សូមគោរពជូនពរដល់យុវជន មិត្តអ្នកអានទាំងអស់សូមទទួលបានជោគជ័យគ្រប់ភារកិច្ច និងកម្លាំងមាំមួនខ្លាំងក្លា ប្រាជ្ញាវាងវៃ រកទទួលទានមានបានគ្រប់ៗគ្នាព្រមទាំងជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# ក្រុមនិស្សិតស្រាវជ្រាវ

## ប្រវត្តិរូបសង្ខេបរបស់ ក្រុមនិស្សិតស្រាវជ្រាវ




### លោក ឡាត់ សៅរិទ្ធ

សមាជិក ស.យ.ជ.ក ជនជាតិដើមភាគតិចព័រ មកពីខេត្តពោសាធ៏  សព្វថ្ងៃលោកកំពុងសិក្សាបន្តនៅរាជធានីភ្នំពេញ ជំនាញភាសាវិទ្យា ឆ្នាំទី៤ និងកំពុងហាត់ការនៅសមាគមយុវជនជនជាតិដើមភាគតិច។



### កញ្ញា មាំង សារ៉ាន់

សមាជិក ស.យ.ជ.ក ជនជាតិដើមភាគតិចទំពួន មកពីខេត្តរតនគិរី សព្វថ្ងៃកញ្ញាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្រ្ត កំពុងធ្វើការនៅសមាគមស្រ្តី ជនជាតិដើមភាគតិចកម្ពុជា។

# ក្រុមនិស្សិតស្រាវជ្រាវ

ប្រវត្តិរូបសង្ខេបរបស់ ក្រុមនិស្សិតស្រាវជ្រាវ



## កញ្ញា សេវ ស្នា

សមាជិក ស.យ.ជ.ក ជនជាតិដើមភាគតិច  ចារាយ សព្វថ្ងៃកញ្ញាកំពុងសិក្សាបន្តនៅរាជធានីភ្នំពេញ ជំនាញអភិវឌ្ឍសហគមន៍ ឆ្នាំទី៤។



## លោក មាយ សំណាង

សមាជិក ស.យ.ជ.ក ជនជាតិដើមភាគតិចពូនង សព្វថ្ងៃកំពុងបន្តការសិក្សា នៅរាជធានីភ្នំពេញ ជំនាញ អក្សរសាស្ត្រខ្មែរ ឆ្នាំទី១។

ក្រុមនិស្សិតស្រាវជ្រាវ

## ប្រវត្តិរូបសង្ខេបរបស់ ក្រុមនិស្សិតស្រាវជ្រាវ



### កញ្ញា ពួយ ស្រីណាង

ជនជាតិដើមភាគតិចចារាយ សព្វថ្ងៃ កំពុងបន្តការសិក្សានៅ រាជធានី ភ្នំពេញ ជំនាញភូមិវិទ្យា និងរៀបចំដែនដី ឆ្នាំទី២។

# បញ្ជីមាតិកា

១

## សេចក្តីផ្តើម

លំនាំបញ្ហានៃការស្រាវជ្រាវ ........ ០១
ចំណោទបញ្ហា ........ ០២
គោលបំណងក្នុងការស្រាវជ្រាវ ........ ០៣
ដែនកំណត់នៃការស្រាវជ្រាវ ........ ០៣
សារៈសំខាន់នៃការស្រាវជ្រាវ ........ ០៣
វិធីសាស្ត្រស្រាវជ្រាវ ........ ០៣

២

## តួសេចក្តី

ប្រវត្តិឃ្មោះ ........ ០៥
វង់ឃ្មោះ ........ ០៥
ទម្រង់ និងរបៀបលេង ........ ០៦
ឃ្មោះប្រើប្រាស់នៅក្នុងកម្មវិធីប្រពៃណី ........ ០៦
ពិធីបុណ្យសព ........ ០៨
របៀបទុកដាក់ឃ្មោះ និងតំណម ........ ០៨
តម្លៃឃ្មោះ ........ ០៩

២

## សេចក្តីបញ្ចប់

អនុសាសន៍ ........ ១០
ឯកសារយោង ........ ១១

## ១.១- លំនាំបញ្ហានៃការស្រាវជ្រាវ

ឃ្មោះគឺជាឧបករណ៍ភ្លេងមួយក្នុងចំណោមផ្សេងៗទៀត ដែលគេសង្កេតឃើញសឹងតែគ្រប់តំបន់នៅក្នុងប្រទេសកម្ពុជា ជាទូទៅឃើញមានប្រើប្រាស់នៅក្នុងកម្មវិធីរៀបមង្គលការ ។ តាំងពីសម័យបុរាណមក ជាពិសេសនៅតាមចម្លាក់ជញ្ជាំងប្រាសាទនានាមកម្រេះ សង្កេតឃើញថាសុទ្ធតែមានការប្រើប្រាស់ឃ្មោះតាមបែបប្រពៃណីជនជាតិដើមភាគតិច និងជនជាតិឡាវ ពាក្យ ឃ្មោះ កើតចេញពីពាក្យ គោះជាឧបករណ៍តន្ត្រីមួយប្រភេទដែលធ្វើឡើងអំពីស្ពាន់ ឬសំរឹទ្ធ។ ឃ្មោះ និងគងស្ថិតក្នុងឧបករណ៍តែមួយ (ពាក្យខ្លះ គេហៅថា«គងឃ្មោះ»)ក៏ប៉ុន្តែមានខ្នាតខុសគ្នា។ ផងមានដោះ រីឯឃ្មោះអត់ដោះ ។ នៅតាមវត្តអារាមខ្មែរបច្ចុប្បន្ននេះ គេប្រើឃ្មោះសម្រាប់គោះហៅពុទ្ធសាសនិកជន ឬប្រមូលផ្តុំអ្នកស្រុកដើម្បីប្រារព្ធពិធីបុណ្យ ឬគេប្រើក្នុងពីធីរៀបអាពាហ៍ ពិពាហ៍ជាដើម ដែលជាសញ្ញាហៅកូនក្រមុំមកសំពះផ្ទឹម ។ វត្តមានឃ្មោះនេះបង្កឱ្យបរិយាកាសរីករាយក៏ដូចជាការបង្ហាញពីភាពអង់អាចក្លាហាន។ នៅសម័យព្រះបាទជ័យ វរ្ម័នទី៧ (១១៦២-១២០១ គ.ស) គេបានប្រើ ឧបករណ៍ភ្លេងជាច្រើនដូចជាគង រគាំង ឃ្មោះ ប្រើក្នុងក្បួនហែទ័ពនៅពេលចេញទៅធ្វើសឹកសង្គ្រាមម្តងៗ ដែលគេរមែងតែងតែឃើញវង់ភ្លេងហែហមតាមក្បួនជានិច្ចដូចជាមានបង្ហាញ នៅក្នុងចម្លាក់លើជញ្ជាំងប្រា សាទបាយ័នជាសក្ខីភាពស្រាប់ដើម្បីជាការលើកទឹកចិត្តក៏ដូចជាជូនពរអោយកងទ័ពយក ឈ្នះលើសត្រូវ ។

លុះមកដល់សម័យទំនើប គឺសម័យអាណានិគមបារាំង (១៨៦៣) វង់ភ្លេងឃ្មោះហែរតាមក្បួនទ័ពក៏ឈប់មានទៀត ក៏ប៉ុន្តែការប្រើឧបករណ៍ភ្លេងនេះនៅតែជ្រួតជ្រាបក្នុងមជ្ឈដ្ឋានប្រជាជនដែលរស់នៅតាមជនបទ វត្តអារាមជាដើម និយមតែងតែលេង ។ ទោះជាសូរ្យតន្ត្រីមានការវិវត្ត យ៉ាងណាក៏ដោយ ក៏ឧបករណ៍ភ្លេងមួយចំនួនធំដែលកើតចេញពីខឿនវប្បធម៌សម័យអង្គរ ឬមុនអង្គរនៅតែរក្សានូវតួនាទី យ៉ាងសំខាន់របស់ខ្លួន។

ឃ្មោះគឺប្រភេទឧបករណ៍ភ្លេងមួយ ធ្វើពីលោហធាតុ ។ ឧបករណ៍នេះមានទំហំខុសគ្នានិងមានអង្កត់ផ្ចិតប្រវែងពី ២០ ទៅ ៦០ ស.ម។ ឃ្មោះធំបំផុតមានអង្កត់ផ្ចិតប្រវែងពី ៩០ ដល់ ១២០ ស.ម ។ សិល្បៈឃ្មោះត្រូវសម្តែងតាមឃ្មោះមួយៗ ឬតាមឈុតឃ្មោះក្នុងឈុតគងឃ្មោះមួយ រួមមានឃ្មោះចាប់ពី២ដល់១២ឬ១៣។ គួរ បញ្ជាក់ផងដែរថាបងប្អូនខ្មែរលើ(ជនជាតិដើមភាគតិច)សព្វថ្ងៃនេះនៅប្រើឧបករណ៍នេះដដែល។ ឧបករណ៍នេះបានឱ្យគេដឹងយ៉ាងច្បាស់នូវចំណាស់ឫសកែវ វប្បធម៌។ អ្វីដែលគួរកត់សម្គាល់ផងដែរនោះ ជនជាតិខ្មែរក៏មានការប្រើប្រាស់ឧបករណ៍ភ្លេងឃ្មោះដែរនៅសម័យអង្គរ គេប្រើឧបករណ៍នេះក្នុងក្បួនដង្ហែទ័ពដោយព្យួរលើឈើច្នក់មួយដែលមានមនុស្សពីរនាក់សែងលើស្មា។

បច្ចុប្បន្ននេះឃ្មោះរបស់អ្នកស្រី ងេះ ខ្លក ដែលជាចាស់ទុំជនជាតិដើមភាគតិចពូនង មានការខូចខាតមួយចំនួន ដែលបណ្តាលមកពីកត្តានៃប្រតិកម្មរវាងអាកុលលើឃ្មោះនេះហើយ ដែលធ្វើឲ្យឃ្មោះកាន់តែមានសភាពស្ទើងទៅៗងាយបែកបាក់ ស្មាមប្រេះ ដោយសារតែជាតិអាកុលកាត់ខ្លាំងព្រមទាំងបានធ្វើឲ្យឃ្មោះ១ក្នុងចំណោមឃ្មោះទាំង៦ បានបាក់បែកនឹងខូចខាតយ៉ាង ខ្លាំងរហូតដល់យើងពុំអាចយកឃ្មោះ១នោះមកលេងបាន។ ដូច្នេះហើយទើបមកដល់សព្វថ្ងៃនៅក្នុងភូមិប្អៀរ ខេត្តក្រចេះមានតែឃ្មោះ៥ប៉ុណ្ណោះដើម្បីលេង ហើយឃ្មោះ៥នេះ បើគ្មានអ្នកចេះលេងដោយខ្វះឃ្មោះ១ទៀត ក៏ពុំអាចលេងបានដែរ ព្រោះវាធ្វើឲ្យសំឡេងឃ្មោះមិនពិរោះនឹងមិនស៊ីចង្វាក់គ្នាដូចពេលដែលឃ្មោះនៅគ្រប់៦នោះឡើយ។ អាចនិយាយបានថា៖ ការសំដែងសិល្បៈឃ្មោះ ដើម្បីបម្រើភ្ញៀវ ទេសចរណ៍គឺជាការធ្វើពិសោធន៍ដ៏សំខាន់មួយរួមចំណែកយ៉ាងសកម្មក្នុងការ ងារអភិរក្សតម្លៃវប្បធម៌ឧបករណ៍ភ្លេងឃ្មោះ។

អត្ថបទនេះ នឹងផ្តោតទៅលើឃ្មោះ របស់ជនជាតិដើមភាគពូនងនៅក្នុងភូមិប្អៀរ ខេត្តក្រចេះ។ ភូមិនេះមានជនជាតិដើមភាគពូនងរស់នៅជាង៨០ភាគរយ ប៉ុន្តែវប្បធម៌ប្រពៃណីប្រឈមនឹងការបាត់បង់ដោយសារឥទ្ធិពលវប្បធម៌ជនជាតិខ្មែរចូលច្រើន។ ភូមិនេះស្ថិតនៅចម្ងាយឆ្ងាយគួរសមពីទីរួមខេត្តក្រចេះ ហើយជាតំបន់ដាច់ស្រយាលមួយ។ នៅក្នុងអត្ថបទនេះផងដែរ ក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវពីការប្រើប្រាស់ឧបករណ៍ភ្លេងឃ្មោះ ដើម្បីទុកជាឯកសារចងក្រង សម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយបានមើល គ្រាន់បានទុកខ្លះក្នុងការស្រាវជ្រាវបន្តទៀត។ គួរបញ្ជាក់ផងដែរថា ទិន្នន័យសម្ភាសន៍ដែលយកមកនេះយើងលើកយកតែក្នុងភូមិប្អៀរ ខេត្តក្រចេះ ហើយអ្នកសម្ភាសន៍ ចាស់ទុំក្នុងភូមិចំនួន៣នាក់ប៉ុណ្ណោះ។

## ១.២- ចំណោទបញ្ហា

ដើម្បីធ្វើការសិក្សាឱ្យមានលក្ខណៈស៊ីជម្រៅនិងមានភាពកាន់តែច្បាស់លាស់ទៅលើប្រធានបទខាងលើ ក្រុមយើងខ្ញុំ បានលើកឡើងនូវចំណោទបញ្ហាមួយចំនួនមកធ្វើការបកស្រាយដែលបញ្ហាទាំងនោះរួមមាន ប្រវត្តិ និង"តើមានបុព្វហេតុអ្វីខ្លះដែលនាំឱ្យមានការ តើមានការបាត់បង់ឧបករណ៍ភ្លេងឃ្មោះ? តើធ្វើដូចម្តេច ដើម្បីរៀបចំឱ្យមានការលេងឧបករណ៍ភ្លេងឃ្មោះនេះឡើងវិញ?

## ១.៣- គោលបំណងក្នុងការស្រាវជ្រាវ

គោលបំណងក្នុងការកំណត់យកប្រធានបទមកធ្វើការស្រាវជ្រាវគឺដើម្បីដឹងអំពីប្រភពរបស់ឧបករណ៍ភ្លេងឃ្មោះ របៀបលេងភ្លេងឃ្មោះតាមបែបប្រពៃណី ពេលមានបុណ្យទានផ្សេងៗ ព្រោះឃ្មោះជាសិល្បៈ មួយដែលមានសារៈសំខាន់ និងមានតួនាទីក្នុងសហគម៍នីមួយៗពេលមានកម្មវិធី។ មិនតែប៉ុណ្ណោះដើម្បីសិក្សាពីបញ្ហាប្រឈមដែលនាំអោយមានការបាត់បង់និងស្វែងរកដំណោះស្រាយ។ ដូច្នេះហើយបានជាក្រុមយើងខ្ញុំសម្រេចជ្រើសរើសប្រធានបទនេះនឹងចុះទៅ សិក្សាស្រាវជ្រាវអំពីឃ្មោះជនជាតិដើមភាគតិចពូនងដែលស្ថិតនៅខេត្តក្រចេះ ភូមិប្លៀរ មកធ្វើជាគោលដៅស្រាវជ្រាវ។

## ១.៤- ដែនកំណត់នៃការស្រាវជ្រាវ

រាល់ការសិក្សាស្រាវជ្រាវប្រធានបទនីមួយៗ គឺតែងតែមានគោលបំណងក្នុងការស្រាវជ្រាវ។ ហេតុនេះអ្វីដែលទាក់ទងនឹងប្រធានបទ "ឧបករណ៍ភ្លេងឃ្មោះជនជាតិដើមភាគតិចពូនង" គឺធ្វើការបកស្រាយនិងសិក្សាស្រាវជ្រាវទៅលើអ្វីដែលទាក់ទងនឹងឃ្មោះជនជាតិដើមភាគតិចពូនងក្នុងភូមិប្លៀរ ខេត្តក្រចេះតែប៉ុណ្ណោះ។ ហើយទិន្នន័យដែលយកមកនេះ យើងជួយសម្ភាសន៍តែចាស់ទុំក្នុងភូមិ៣នាក់ប៉ុណ្ណោះ និងសិក្សាពីឯកសារមួយចំនួនដែលអ្នកស្រាវជ្រាវមុនបានចងក្រងអំពីឧបករណ៍ភ្លេងឃ្មោះ។

## ១.៥- សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវទៅលើប្រធានបទខាងលើនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ដល់យុវជន ចាស់ទុំ មិត្តអ្នកអាន អ្នកស្រាវជ្រាវ ព្រមទាំងសាធារណជនទាំងអស់ឱ្យបានយល់ដឹងកាន់តែច្បាស់និងស៊ីជម្រៅអំពីការប្រើប្រាស់ឃ្មោះជនជាតិដើមភាគតិចពូនងក្នុងភូមិប្លៀរ ខេត្តក្រចេះ របៀបលេងឧបករណ៍ភ្លេងឃ្មោះតាមបែបប្រពៃណី ពេលមានបុណ្យទានផ្សេងៗ ព្រោះឃ្មោះជាសិល្បៈមួយដែលមានសារៈសំខាន់ និងតួនាទីក្នុងសហគម៍នីមួយៗពេលមានកម្មវិធី។

## ១.៦- វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវបែបសកម្មភាពសិក្សានេះ ផ្តោតសំខាន់លើវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យយើងធ្វើការប្រមូលទិន្នន័យ និងព័ត៌មានផ្សេងៗតាមរយៈការសំយោគឯកសារពាក់ព័ន្ធ នឹងបទសម្ភាសន៍ផ្ទាល់ និងតាមអនឡាញជាមួយភាគីពាក់ព័ន្ធ ព្រមទាំងការពិភាក្សាក្រុមជាមួយសហគមន៍មូលដ្ឋានដែលជាជនជាតិដើមភាគតិចពូនង ដោយចុះសម្ភាសន៍ផ្ទាល់នៅតំបន់នោះ។ យើងបានសម្ភាសន៍អ្នកពាក់ព័ន្ធសំខាន់ៗសរុបចំនួន ៣នាក់ ក្នុងនោះមានសហគមន៍មូលដ្ឋានដែលជាចាស់ទុំក្នុងភូមិ និងមានស្ត្រីជាជនជាតិដើមភាគតិចពូនង។ ការសម្ភាសន៍បែបសួរនាំពីចាស់ទុំ ធ្វើតាមយុទ្ធសាស្ត្រសម្ភាសន៍បែបសាមញ្ញ ស៊ីជម្រៅបែបគុណភាព ក្នុងគោលបំណងដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធពីប្រធានបទ។



រូបភាពទី១៖ សកម្មភាពក្រុមអ្នកសិក្សាស្រាវជ្រាវ ចុះសម្ភាសន៍ចាស់ទុំអំពីឧបករណ៍ភ្លេងឃ្មោះ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥។
នៅផ្ទះលោក អ៊ុំចុក គ្រាត
[ប្រភពរូបភាព៖ មាយ សំណាង]

## ២.១ -ប្រវត្តិឃ្មោះ

ឃ្មោះជាឧបករណ៍ភ្លេងម្យ៉ាង (ភាសាពូនងខេត្តក្រចេះ ក៏ហៅថា ឃ្មោះដែរ) មានតាំងពីយូរណាស់មកហើយ យើងមិនដឹងថាតាំងពីពេលណាទេ ប្រហែលជាក្នុងជំនាន់ព្រះបាទជ័យវរ្ម័នទី៧ និងទី៨(អាចមុននេះ) កើតមកភ្លាមឃើញមានភ្លាម តាំងពីជំនាន់ឪពុកម្តាយ តមក២ទៅ៣ជំនាន់មកហើយ។ ឃ្មោះនេះមានប្រភពមកពីវៀតណាម ព្រោះនៅវៀតណាម ក៏មានជនជាតិដើមភាគតិចពូនងផងដែរ ដែលរស់នៅទីនោះ តាមរយៈការធ្វើជំនួញ លក់ដោះដូរទំនិញគ្នា ឬនាំយកតាមរយៈបងប្អូន សាច់ញាតិជាដើម។ ឃ្មោះមានសភាពខុសពីគង ដែលគងភាគច្រើនមាននៅខេត្តមណ្ឌលគិរី និងខេត្តរតនគិរី តែឃ្មោះក៏មាននៅទីនោះដែរ ប៉ុន្តែមិនសូវពេញនិយមប្រើប្រាស់ដូចគងទេ ដែលជនជាតិដើមភាគតិចនៅទីនោះនិយមយកលេង នៅពេលមានកម្មវិធី និងការសែនព្រេនបែបប្រពៃណីផ្សេងៗ។ បើគេនិយាយអំពីគង និងឃ្មោះ គឺខុសគ្នាត្រង់ថាគងមានដោះ ហើយឃ្មោះមិនមានដោះនោះទេ។ ភាគច្រើនឃ្មោះធ្វើអំពីស្ពាន់ ហើយក៏មានខ្លះទៀតក៏មានធ្វើអំពីសំរឹតទៀតផង។ តាមសម្តីរបស់អ្នកស្រីដែលជាម្ចាស់ឃ្មោះនេះ មូលហេតុដែលឃ្មោះអ្នកស្រីមានការបាក់បែក ដោយសារតែពេលអ្នកដែលមកមើលឃ្មោះនេះមួយចំនួន តែងតែយកអាកុលចាក់លើ ឃ្មោះដើម្បីពិសោធន៍ថាតើរបស់នោះ ជាសំរឹត ឬមិនមែនសំរិទ្ធ។ ពាក្យ «ឃ្មោះ » (ន.) គ្រឿងវាយដំប្រគំធ្វើដោយសំរិទ្ធ ដោយស្ពាន់មានសណ្ឋានដូចគងធំ តែគ្មានដោះ។ (វចនានុក្រមខ្មែរ)

## ២.២ -វង់ឃ្មោះ

ក្នុងវង់ភ្លេងប្រពៃណីជនជាតិដើមភាគតិចពូនងនៅភូមិប្អៀរនេះមានតែវងឃ្មោះនេះទេ ដែលគេនិយមលេងប៉ុន្តែកាលពីបុរាណក៏មានឧបករណ៍ភ្លេងមួយឈ្មោះថា«គងរៀន» ស្រដៀងទៅនឹង «ចាប៉ីឃ្លោក» ប៉ុន្តែគេហៅ «គងរៀន» បច្ចុប្បន្ននេះបាត់បង់អស់ហើយ ។ បច្ចុប្បន្នវង់ឃ្មោះ មានការបាក់បែកមួយចំនួន តែក៏អាចនៅលេងបាន គ្រាន់តែពិបាកបន្តិចព្រោះវង់ឃ្មោះដែលអាចលេងបានមាន ៥ទៅ៦ឃ្មោះ ទើបអាចលេងបានពិរោះ ប្រសិនបើចំនួនឃ្មោះមិនមានគ្រប់ទេ គេក៏លេងមិនកើតដែរ ព្រោះធ្វើអោយចង្វាក់និងភ្លេងមិនចូលគ្នា។តាមសម្តីរបស់អ្នកស្រីដែលជាម្ចាស់ឃ្មោះនេះ មូលហេតុដែលឃ្មោះនេះមានការបាក់បែក ដោយសារ តែពេលអ្នកដែល



រូបភាពទី២៖ ឧបករណ៍ភ្លេងឃ្មោះ
របស់សហគមន៍ភូមិប្អៀរ
ប្រភពរូបភាព៖ មាឃ សំណាង

មកមើលឃ្មោះនេះមួយចំនួន តែងតែយកអាកុលចាក់លើ ឃ្មោះដើម្បីពិសោធន៍ថាតើរបស់នោះ ជាសំរឹតឬជាអ្វី? ឃ្មោះមានទំហំតូចធំ ខ្លះក៏តូច ឯខ្លះទៀតក៏ធំទៅតាមខ្នាតរបស់វា។ នេះបើតាមប្រសាសន៍អ្នកស្រី ងេះ ខួក ជាចាស់ទុំជនជាតិដើមភាគតិចពូនងបានអោយដឹងថា បច្ចុប្បន្ននេះវង់ឃ្មោះនៅសល់តែ៩ប៉ុណ្ណោះ។ ហើយនៅក្នុងភូមិនេះមិនមាននរណាមានទេ មានតែគ្រួសារអ្នកស្រីមួយ។ អ្នកស្រីបន្ថែមទៀតថា នៅពេលគេត្រូវការជួលអោយលេង អ្នកស្រីនឹងទាក់ទៅបងប្អូនដែលនៅភូមិផ្សេងមកលេងបានព្រោះពួកគាត់ទាំងនោះក៏មានឃ្មោះដែរ និងចេះលេងថែមទៀត។

## ២. ៣-ទម្រង់ និងរបៀបលេង

ការលេងឃ្មោះនេះ មានទម្រង់ខុសៗគ្នាទៅតាមជំនាញរបស់ក្រុមអ្នកលេង តែក៏អោយត្រូវចង្វាក់គ្នាដែរ នៅក្នុងការលេងនេះមានច្រើនទម្រង់ យើងមិនលេងតែមួយទម្រង់នោះទេ។ ការលេងឃ្មោះនេះ មិនតម្រូវអោយមានអ្នកច្រៀងនោះទេ ឬចម្រៀងនោះទេតែបើអ្នករពិសមាត់ ក៏អាចច្រៀងបានដែរ តែភាគច្រើនគេសង្កេតឃើញមិនសូវមានអ្នកច្រៀងនោះទេនៅពេលលេង។ ការលេងឃ្មោះគឺមិនប្រកាន់ចំពោះនរណាម្នាក់នោះទេ មិនថាជាយុវជន ក្មេង ចាស់ ប្រុស ឬស្រី សំខាន់អោយតែពួកគាត់ចេះលេងហើយអាចលេងបាន។ ចំនួនអ្នកលេងឃ្មោះ និងឃ្មោះត្រូវមានឱ្យគ្រប់ បើឃ្មោះ៦ អ្នកលេងក៏ត្រូវមាន៦នាក់ដែរ មិនអាចខ្វះនរណាម្នាក់បានទេ។

## ២.៤-ឃ្មោះប្រើប្រាស់នៅក្នុងកម្មវិធីប្រពៃណី ផ្សេងៗ

ឧបករណ៍ភ្លេងឃ្មោះមានតួនាទីសំខាន់ខ្លាំងណាស់នៅក្នុងកម្មវិធីរបស់ជនជាតិដើមភាគតិចពូនង ភូមិប្អៀរ ដែលតម្រូវអោយលេងឃ្មោះនេះជាដាច់ខាតនៅពេលកម្មវិធីប្រពៃណី។ នៅពេលលេង គេប្រើដៃគោះ ឬមានកូនឈើឬដុំឈើខ្លីៗ ដែលអាចកាន់នឹងដៃគោះនោះទេភាគច្រើនគេប្រើដៃជំនួស អាចថាជាវប្បធម៌របស់ពួកគាត់ប៉ុន្តែយើងប្រើឈើ ក៏ដូចជាមិនមានបញ្ហាអ្វីដែរ។ ទម្រង់នៃការលេងឃ្មោះ មានផ្សេងៗគ្នាដែលធ្វើអោយសំលេងឃ្មោះខុសៗគ្នាទៅតាមនេះដែរ វាអាស្រ័យលើក្រុមអ្នកលេង ថាតើចង់បានចង្វាក់បែបណា តែតាមការសង្កេតឃើញភាគច្រើនគេប្រើចង្វាក់រាំវង ឬចង្វាក់ភ្លេងមិនសូវញាក់។ បើអ្នកមិនចេះលេង គឺពិបាកក្នុងការលេងអោយត្រូវនឹងចង្វាក់ណាស់ដែលអាចធ្វើអោយមិនពិរោះ នាំអោយអ្នកស្តាប់ធុញថប់ផងដែរ។ ដើម្បីលេងឃ្មោះនេះបានពិរោះ ត្រូវមានការហាត់រៀនសមជាមុន ហើយការហាត់អាចចំណាយពេលយូរ ឬឆាប់តាមទេពកោសល្យរបស់អ្នករៀនជាក់ស្តែង ។



រូបភាពទី៣៖ ឧបករណ៍ភ្លេងឃ្មោះ លាបរមៀតនៅពេលសែនព្រេន
របស់ជនជាតិដើមភាគតិចពូនង [ប្រភពរូបភាព៖ មាឃ សំណាង]

គេនិយមលេងឃ្មោះ នៅក្នុងកម្មវិធីផ្សេងៗ ដូចជា សែនស្រូវ ការរៀបការ សែនភូមិ សិល្បៈរបាំ ឬគេលេងដើម្បីទទួលអ្នកធំ អ្នកតូចចុះមក វប្បធម៌ឃ្មោះតភ្ជាប់នឹងជីវភាពរស់នៅរបស់គេ។ សម្លេងឃ្មោះបានជិតស្និទ្ធជាមួយមនុស្ស តាំងពីពេលកើតមករហូតដល់ពេលគេស្លាប់ទៅវិញ។ ដូច្នេះសិល្បៈឃ្មោះបានសម្តែងក្នុងពិធីដាក់ឈ្មោះ ពិធីបុណ្យសប្បាយរីករាយចំពោះរដូវប្រមូលផលស្រូវជាច្រើនសន្ធឹក ពិធីបុណ្យចាក់ក្របី ពីធីបុណ្យបួងសួងសុំទឹកភ្លៀង ពិធីអាពាហ៍ពិពាហ៍ ពិធីបុណ្យឡើងគេហដ្ឋានថ្មី សិល្បៈឃ្មោះគឺជាសម្លេងដ៏អាថ៌កំបាំងដែលតភ្ជាប់រវាងភពកណ្តាលនិងភពអាទិទេពផងដែរ។ ដើម្បីបង្ហាញពីការស្វាគមន៍និយាយអោយចំ គឺគេនិយមលេងឃ្មោះនៅក្នុងកម្មវិធីបែបសប្បាយៗ មានជាការរាំរែកជាដើម ដែលគេហៅថា«កម្មវិធីគក់ឃ្មោះ» ។

នៅពេលខ្លះមានអង្គការចុះមកគេរកទៅលេង ដើម្បីជាការបង្ហាញពីវប្បធម៌របស់ជនជាតិដើមពូនង។ កាលជំនាន់ដើម ពេលអ្នកស្រុកប្រមូលផលដំណាំរួចរាល់ យប់ឡើងគេនាំគ្នាជួបជុំផឹកស៊ីបែបប្រពៃណី ពេលស្រវឹងមនុស្សតែងតែចង់រាំរែក ដូច្នេះមានតែភ្លេងឃ្មោះនេះ ហើយដែលជាវត្ថុមានមួយសំខាន់សម្រាប់ពួកគាត់ និងញ៉ាំងអោយបរិយាកាសសប្បាយរីករាយក្នុងពេលមួយរាត្រី។ ពេលខ្លះគេរកយើងទៅលេង ដើម្បីបង្ហាញអោយគេមើល ឬពេលខ្លះមានអង្គការណាមួយចុះមកគេអោយយើងលេង ដើម្បីជាការបង្ហាញពីវប្បធម៌របស់យើង។

## ២.៥ - ពិធីបុណ្យសព

នៅក្នុងកម្មវិធីបុណ្យសព យើងសង្កេតឃើញថា ជនជាតិដើមភាគតិចពូនង មានទំនៀមទម្លាប់មួយដែលស្រដៀងទៅនឹងជនជាតិខ្មែរដែរ នៅពេលមានមនុស្សស្លាប់ថ្មីៗ គេនៅស្រណោះស្រណោក ពោលគឺគ្រួសារសពកំពុងកាន់ទុក្ខ ដូច្នេះនៅក្នុងពិធីបុណ្យសព គេមិនលេងឃ្មោះទេលុះត្រាតែបុណ្យ១០០ថ្ងៃ និង៣ឆ្នាំ ទើបអាចលេងបាន និយាយរួមនៅពេលដែលគ្រួសារសពបានស្រាកស្រាន្តពីការកាន់ទុក្ខហើយទើបអាចលេងបាន។ ការប្រតិបត្តិនេះ មានរហូតមកបច្ចុប្បន្នសម្រាប់ជនជាតិដើមភាគតិចពូនងនៅសហគមន៍ភូមិប្អៀរនេះ។

## ២.៦ -របៀបទុកដាក់ឃ្មោះ និងតំណម



រូបភាពទី៤៖ ការព្យួរឧបករណ៍ភ្លេងឃ្មោះ តាំងពីព័ណ៌ ឬការរក្សាទុក
(ប្រភពរូបភាព៖ ហ្វេបសាយ វប្បធម៌ថែរក្សាសិល្បៈគងឃ្មោះ តីង្វៀន

ជាទូទៅនៅក្នុងការប្រើប្រាស់ឃ្មោះនេះ មុននឹងយកលេងក្នុងពិធីផ្សេងៗត្រូវសែនព្រេនហើយនៅពេលលេងរួច ត្រូវរៀបចំទុកដាក់អោយបានត្រឹមត្រូវ ការទុកដាក់នេះទៀតសោត គឺតម្រូវអោយដាក់ ឬចងព្យួរដាក់លើក្បាលដំណេករបស់យើង អោយបានត្រឹមត្រូវ ជៀសវាងការទុកដាក់គរលើគ្នា ពីព្រោះតំណមក្នុងការទុកដាក់ឃ្មោះមិនអាចទុកគរគ្នាបានទេ ព្រោះរបស់ទាំងនោះ សុទ្ធតែមានព្រលឹងតាមថែរក្សា ការពារប្រៀបដូចជាព្រះ ឬអ្នកថែរក្សាផ្ទះយើងដែរ ព្រោះពេលយើងសែនព្រេន មានការច្រូចឈាមមាន់ ឈាមទា ដែលធ្វើអោយឃ្មោះនេះ ក្លាយទៅជាវត្ថុស័ក្តិសិទ្ធ មានអ្នកកាន់ នៅថែរក្សា។ ម្យ៉ាងវិញទៀត ត្រូវទុកដាក់អោយផុតពីដៃក្មេង បើយើងទុកដាក់មិនបានប្រុងប្រយ័ត្នទេ ឬមានក្មេងយករបស់នោះលេងផ្តេសផ្តាសនឹងនាំអោយឈឺ ឬមានពេលខ្លះអាចជាព្រលឹងលងបន្លាចអោយក្មេងនោះឈឺ តែពេលយើងសែនព្រេន បន់ស្រន់ទៅសុំការខមាទោស ទើបបានជាដូចដើមវិញ។ មួយវិញទៀតប្រសិនបើមានកូនកំលោះឬកូនក្រមុំណានៅក្នុងផ្ទះបានខូចខិលគ្នាមិនទាន់អោយចាស់ទុំដឹងឮព្រលឹងដែលថែរក្សាឃ្មោះនេះ គឺធ្វើអោយកូនចៅក្នុងផ្ទះទាំងអស់ឈឺគ្រុនថែមទៀត ។

ឃ្មោះនេះប្រៀបបានដូចជាព្រលឹងអារក្សអ្នកតាដែលតាមថែរក្សាក្នុងផ្ទះយើង ដូច្នេះដែរបើផ្ទះណាមានឃ្មោះ រមែងមានអ្នកថែរក្សាអោយចម្រុងចម្រើង។ ការប្រើប្រាស់ឃ្មោះនេះមានតំណម គឺថានៅពេលលេង យើងត្រូវសែនព្រេន មានតំណមសែនព្រេនប្រាប់ដល់ដូនតា អ្នកថែរក្សារឃ្មោះនេះ និងត្រូវប្រាប់ពីកម្មវិធីដែលយើងត្រូវលេងនោះផងដែរ។ ចំពោះការខ្ចីយកទៅប្រើប្រាស់ ទោះបីយើងមិនមែនជាម្ចាស់ឃ្មោះក៏ដោយក៏យើងអាចខ្ចីយកទៅលេងបានដែរ តែត្រូវសែនព្រេនប្រាប់ទៅដល់អ្នកថែរក្សា ពីព្រោះគេជឿថាក្នុងឃ្មោះនោះមានព្រលឹងដួងវិញ្ញាណស្ថិតនៅថែរក្សា ។

## ២.៧- តម្លៃឃ្មោះ

កាលពីបុរាណ ឃ្មោះមានតម្លៃស្មើទៅនឹងក្របីមួយក្បាលក្នុង១ឃ្មោះ(ក្របីធំ) ប្រសិនបើយើងចង់ជាវជាលុយក៏បាន ហើយដូរជាក្របីក៏បាន។ ប៉ុន្តែសម័យនេះ ពិបាកក្នុងការរកទិញណាស់ ភាគច្រើនអាចមាននៅខេត្តរតនគិរី និងមណ្ឌលគិរី។ ម្យ៉ាងទៀតនៅពេលដែលយើងទទួលបានឃ្មោះយកពីម្ចាស់គេនោះ យើងត្រូវមានការសែនព្រេនដើម្បីជាការស្វាគមន៍ព្រលឹងគេមករស់នៅក្នុងផ្ទះយើង ឬសែនប្រាប់ពីម្ចាស់ដើមមកម្ចាស់ថ្មី គ្រឿងសែនមានដូចជាជ្រូក ស្រា មាន់ជាដើម ដើម្បីទទួលគេ។

## ៣- អនុសាសន៍

-ប្រសាសន៍លោកតាផ្យ៉ាង ណិះ ដែលជាចាស់ទុំក្នុងភូមិ បាននិយាយថា៖ លោកតាចង់អោយក្មេងៗជំនាន់ក្រោយ ចេះលេងឃ្មោះនេះណាស់ ប៉ុន្តែយុវជនហាក់បីដូចជាមិនយកចិត្តទុកដាក់នោះទេ នាំគ្នាគិតតែពីបទចម្រៀងទាន់សម័យ ដោយគិតថាការលេងឃ្មោះនេះហួសសម័យ។

-ចាស់ព្រឹទ្ធាចារ្យក្នុងភូមិ ដូចជាលោកតាជាដើម ចង់អោយមានអ្នកបន្តវេនណាស់ តែយុវជនមិនព្រមហាត់រៀន និងមិនឃើញមានថាយុវជនណាចង់បន្តរៀនសូត្រ និងរកថែរក្សាវប្បធម៌ ។ លោកតាបានបន្ថែមទៀតថា ទោះបីជាលោកតាចាស់ក៏ដោយ កម្លាំងមិនសូវខ្លាំងដូចមុន ភ្លេចមុខ ភ្លេចក្រោយ ប៉ុន្តែអោយតែមានយុវជន ចង់ហាត់រៀន លោកតានៅតែខំប្រឹងទៅបង្ហាត់បង្រៀនដោយឥតខ្លាចនឿយហត់ ឬគិតថ្លៃឈ្នួលអ្វីនោះទេ។

-អ្នកពាក់ព័ន្ធ ដូចជាអង្គការជនជាតិដើមភាគតិច និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងការជួយលើកស្ទួយនូវឧបករណ៍ភ្លេងឃ្មោះនេះ តាមរយៈការបង្កើតអោយមានកម្មវិធីផ្សេងៗដែលអាចជួលអោយក្រុមអ្នកលេងឃ្មោះបានលេង ដើម្បីជាការបង្ហាញពីវប្បធម៌ និងជួយគៀងគរអោយយុវជនបានចូលរួមក្នុងការហាត់លេងឧបករណ៍ភ្លេងឃ្មោះ ឬបង្កើតជាកន្លែងសម្រាប់ហាត់បង្រៀនកាន់តែល្អ។

# ឯកសារយោង

១ - គងឃ្មោះ-សម្លេងពិសេសបន្លឺឡើងនៅកណ្តាលតំបន់ព្រៃភ្នំ(២៤/៥/២០១៧)។
២- វចនានុក្រមខ្មែរអេឡិកត្រូនិច(២០២២)។
៣- បណ្ឌិត សំ សំអាង(១២/៧/២០២១) អត្ថបទគង និងវង់គងជនជាតិដើមភាគតិចកម្ពុជា។
៤- មហោស្រពគងជនជាតិភាគតិច(២០១៨) រៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងគណៈអភិបាលខេត្តរតនគិរី នាទីក្រុងបាលុង ខេត្តរតនគិរី។
៥-តំណភ្ជាប់ វីដេអូលេងឃ្មោះ ( https://www.youtube.com/watch?v=QqBlPbVuz3Y)
៦- ទទួលព័ត៌មានពីចាស់ទុំសហគមន៍៣រូប ៖ ១. លោកតា ផ្សាង ណិះ ២- លោកអ៊ុំ ចុក គ្រាត ៣- អ្នកស្រី ងេះ ខ្លុក (២៤/១២ /២០២៥ )។

សមាគមយុវជនជាតិដើមភាគតិចកម្ពុជា
Cambodia Indigenous Youth Association

## ព័ត៌មានបន្ថែមអំពីយើង៖

+៨៥៥ ១២ ៨២៩ ៧១៧ info@ciyanet.org www.ciyanet.org

## អាសយដ្ឋាន៖

#ផ្ទះលេខ ២៨, ផ្លូវលេខ ៤៦០, សង្កាត់ទួលទំពូង ខណ្ឌ
មានជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ចងក្រងដោយ៖ ក្រុមនិស្សិតជនជាតិដើមភាគតិច

កាលបរិច្ឆេទ ៖ ខែធ្នូ ឆ្នាំ២០២៥